## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
## (គ.ជ.ប)

# សៀវភៅណែនាំ

## ស្ដីពី

## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
## នីតិកាលទី៤

# មាតិកា

**ទំព័រ**


**អក្សរកាត់** ---- i

**គោលបំណង** ---- ii

**ជំពូកទី ១ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង** ---- ១

**ផ្នែកទី ១ ការប្តឹងតវ៉ា ឬការប្តឹងជំទាស់** ---- ១

១. ពាក្យបណ្តឹង ---- ១

២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ---- ២

**ផ្នែកទី ២ បណ្តឹងក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** ---- ៣

១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ---- ៣

២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ---- ៣

៣.ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ---- ៤

៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ---- ៤

៥. ការពិនិត្យសម្រេចរបស់ គ.ជ.ប ---- ៦

៦. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---- ៦

៦.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---- ៦

៦.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ---- ៧

**ផ្នែកទី ៣ បណ្តឹងក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង** ---- ៩

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ---- ៩

១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប ---- ៩

១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ---- ១២

២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ---- ១៣

២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ——————— ១៣
២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ——————— ១៥
៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ – ១៦
៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ—— ១៦
៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ———— ១៦
**ផ្នែកទី ៤ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ព.ស ដែលអាចនាំឱ្យមានការផាកពិន័យ** ——————— ១៩
I. **ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម** ——————— ១៩
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប ——— ១៩
១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប ——————— ១៩
១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប ——————— ២១
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប —— ២៤
២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ——————— ២៤
២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ——————— ២៥
៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ -២៧
៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ——២៧
៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ———— ២៨
II. **បណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត** ——————— ៣០
**ផ្នែកទី ៥ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត**—— ៣២
១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ ——៣២
១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ ——————— ៣២

១.២ ការដោះស្រាយអំពីការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ ——៣២
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប —— ៣៣
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប —————— ៣៣
២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប——————————៣៥
៣.ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប —— ៣៧
៣.១ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប —————— ៣៧
៣.២ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ——————————៣៨
**ផ្នែកទី ៦ បណ្តឹងក្នុងដំណាក់កាលប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត**————————————————————————៤២
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប– ៤២
១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប——————— ៤២
១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ———————————៤៣
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ —— ៤៤
២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ —— ៤៤
២.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ———— ៤៤
**ផ្នែកទី ៧ នីតិវិធីអនុវត្តសេចក្តីសម្រេចស្តាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់**———————————————————————៤៦
**ជំពូកទី ២ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង** ——————————————————— ៤៧
**ផ្នែកទី ១ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ**—————— ៤៧
១. សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ————————————————————៤៧
១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ————————————————————៤៧
១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ——————————————— ៤៨

២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ —— ៤៩
២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ឧប —— ៤៩
២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប —— ៤៩
**ផ្នែកទី ២ សិទ្ធិ និងភារកិច្ចរបស់គូភាគី ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី** —— ៥១
១. សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី —— ៥១
២. សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្ដឹង —— ៥២
៣. សិទ្ធិ និងកាតព្វកិច្ចរបស់ចុងចម្លើយ —— ៥២
៤. សិទ្ធិ និងកាតព្វកិច្ចរបស់មេធាវី ឬតំណាង —— ៥៣
៥. សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី —— ៥៣
**ផ្នែកទី ៣ នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ** —— ៥៤
១. ប្រភេទសវនាការ —— ៥៤
២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ —— ៥៥
៣. ពេលវេលាដោះស្រាយពាក្យបណ្ដឹង —— ៥៥
៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការ —— ៥៥
៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេចនៅ គជ.ឧប —— ៥៥
៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប —— ៥៥
៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ —— ៥៦
៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ —— ៥៧

៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ------ ៥៩
៨. មធ្យោបាយបង្ហាញភ័ស្តុតាង ------------------------------------------ ៦០
៩. ការប្រើប្រាស់ និងបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣)-------- ៦០
១០. ទម្រង់ផ្សេងៗសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និង
សវនាការ ---------------------------------------------------------- ៦២
**ឧបសម្ព័ន្ធ**----------------------------------------------------------------------- ៦៣
**ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)** ------------------- ៦៣
**ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)**------ ៦៤
**ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំ
សម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង**------------ ៦៥
**ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារសង្ខេប**---------------------------------- ៦៦

# អក្សរកាត់

| | |
|---|---|
| - ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា | ច.ប.ព.ស |
| - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| - បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា | ប.ន.ព.ស |
| - គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| - គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| - លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| - ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| - គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| - ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| - ទម្រង់បែបបទលេខ | ទ. |
| - ទម្រង់បែបបទពាក្យបណ្តឹង | ទ.១២០២ |
| - ទម្រង់បែបបទសម្រង់សេចក្តីសម្រេច | ទ.១២០៣ |

# គោលបំណង

សៀវភៅណែនាំស្តីពី**នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤** ត្រូវបានរៀបចំឡើងដោយផ្អែកលើ ច.គ.ជ.ប ច.ប.ព.ស ច.ប.ត.រ និង ប.ន.ព.ស ។

សៀវភៅណែនាំនេះ រៀបចំឡើងដើម្បីជាជំនួយស្មារតីសម្រាប់មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ ឱ្យបានយល់ដឹងអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ។ សៀវភៅណែនាំនេះ ចែកចេញជាពីរជំពូក ៖

**ជំពូកទី ១** បង្ហាញដោយសង្ខេបអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ។

**ជំពូកទី ២** បង្ហាញដោយសង្ខេបអំពីនីតិវិធីប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង ដែលកើតមានឡើងនៅគ្រប់ដំណាក់កាល ក្នុងនោះមានជាអាទិ៍ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាជំនុំជម្រះ ប្រភេទសវនាការ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង។

ផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះមាន ៤ ឧបសម្ព័ន្ធ ៖

- ឧបសម្ព័ន្ធទី ១ ទម្រង់បែបបទពាក្យបណ្តឹង (ទ.១២០២)
- ឧបសម្ព័ន្ធទី ២ ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)
- ឧបសម្ព័ន្ធទី ៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង
- ឧបសម្ព័ន្ធទី ៤ នីតិវិធី និងខ្លឹមសារនៃសម្បថ ។

# ជំពូកទី ១
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង

## ផ្នែកទី ១
## ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់តាមឋានានុក្រមទៅ គធ.ឃប ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ អំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ព.ស និង ប.ន.ព.ស ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្ដឹងតវ៉ា និងការប្ដឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះដែលត្រូវប្ដឹងដោយសាមីគណបក្សនយោបាយ ឬសាមីបេក្ខជន ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវប្ដឹងដោយមន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្ដឹងដោយគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត។

### ១. ពាក្យបណ្ដឹង

ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្ដឹងជំទាស់**) ។ ទ.១២០២ នេះ ត្រូវបានប្រគល់ជូនអ្នកប្ដឹងដើម្បីប្ដឹង ឬប្ដឹងបន្ត ប្រសិនបើមានការស្នើសុំ។

អ្នកប្ដឹងដំបូងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជូសខ្លួនបាន។

ពាក្យបណ្ដឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង។
២- កម្មវត្ថុនៃបណ្ដឹង។
៣- ប្រភេទនៃអំពើល្មើស។
៤- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង និងលក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត។
៥- បើអាចធ្វើបានបញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលបានរំលោភ។

៦- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ ឬភាពមិនប្រក្រតី។

៧- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (បើមាន)។

៨- សេចក្ដីអះអាងគាំទ្រ ភ័ស្ដុតាងផ្សេងៗទៀត (បើមាន)។

៩- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (បើមាន)។

ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាបណ្ដឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

ពាក្យបណ្ដឹងប្ដឹងពីអញ្ញាតជន[១] ត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គធ.ខប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្ដឹងវិញអំពីករណីនេះ ក្នុងរយៈពេលសមស្រប។

**២. ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្ដឹងតវ៉ា ឬ បណ្ដឹងជំទាស់**

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យផ្លូវការទេ។

[១] ជនមិនស្គាល់អត្តសញ្ញាណ

## ផ្នែកទី ២
## បណ្តឹងក្នុងដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ១. ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប្រជាពលរដ្ឋខ្មែរត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរពីកំណើត

២- មានអាយុ ៤០ (សែសិប) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

៣- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

៤- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា

៥- មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។

### ២. ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាគឺ៖

១- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៣- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៤- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ឬ

៦- សមាជិក គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

៧- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៨- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

**៣. ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាពត្រូវផ្ញើជូន គ.ជ.ប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការឃោសនាបោះឆ្នោត។

**៤. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ**

**ក.** គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ហើយមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាម ទ.១០០៨ មក គ.ជ.ប ។ ទ.១០០៨ នេះ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ។

**ខ.** ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០ នាទី ដល់ ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ ១៧:៣០ នាទី។

**គ.** ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវធ្វើជា ២ (ពីរ) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ៖

១- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់

២- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ

៣- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ

៤- បញ្ជីបេក្ខជនឈរឈ្មោះសរុបទូទាំងប្រទេស។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងព្រឹទ្ធសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិដោយមិនគិតអាសនៈដែលត្រូវបានចាត់តាំង និងជ្រើសតាំង។

៥- ឈ្មោះភូមិភាគដែលគណបក្សនយោបាយមានបំណងទៅឈរឈ្មោះ និងបញ្ជីបេក្ខជនឈរឈ្មោះភូមិភាគទាំងនោះ។ បញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគត្រូវមានបេក្ខជនគ្រប់តាមចំនួនអាសនៈ និងបំពេញតាមគំរូដែល គ.ជ.ប ផ្តល់ឱ្យ។

៦- សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

៧- លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ស្តីពីការបង្កើតគណបក្សនយោបាយ។

៨- សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ព.ស ច.ប.ត.រ ប.ន.ព.ស ក្រមសីលធម៌របស់ គ.ជ.ប និងច្បាប់ស្តីពីគណបក្សនយោបាយ។

៩- បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ។

១០- បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះ បានទទួលសន្លឹកឆ្នោតយ៉ាងតិច ៣ (បី) ភាគរយនៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈ ១ (មួយ) ក្នុងព្រឹទ្ធសភា។

**៥. ការពិនិត្យសម្រេចរបស់ គ.ជ.ប**

ក. គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

ខ. ក្នុងករណីយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ។

គ. ក្នុងករណីពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយ ពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥.១ ៥.២ ៥.៣ ៥.៤ និង ៥.៦ នៃ ប.ន.ព.ស គ.ជ.ប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ឬកែតម្រូវចំណុចខ្វះខាត ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។

ឃ. ប្រសិនបើសាមីគណបក្សនយោបាយមិនបានបំពេញបន្ថែម ឬកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលកំណត់ទេ គ.ជ.ប ត្រូវចេញសេចក្តីសម្រេច (ទ.១២០៣) បដិសេធពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ចំនួន ៣ (បី) ច្បាប់ រួចត្រូវផ្ញើជូនសាមីគណបក្សនយោបាយ ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ហើយផ្តល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាងថា គាត់អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

**៦. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

**៦.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

ក. គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប សាមីគណបក្សនយោបាយ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

ខ. ក្នុងករណីទទួល ទ.១២០៣ ហើយ ប៉ុន្តែសាមីគណបក្សនយោបាយ ឬតំណាង ពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅតាមពេលវេលាកំណត់ទេ ត្រូវចាត់ទុកថាសាមីគណបក្សនយោបាយនោះបានបោះបង់ចោលការសុំចុះបញ្ជីគណបក្សនយោបាយជាស្ថាពរ។

គ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**៦.២ ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើពាក្យបណ្តឹងតវ៉ានេះក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

ខ. នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

គ. ក្នុងករណីយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

ឃ. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

## ៧. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង



## ផ្នែកទី ៣
## បណ្ដឹងក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬនិងប្ដឹងជំទាស់ជា លាយលក្ខណ៍អក្សរ តាម ទ.១២០២ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ គឃ.ខប ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

**ពាក្យបណ្ដឹងតវ៉ា** អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម៖

- សាមីអ្នកប្ដឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិក កបឃ.ស ក្នុងតំណែង ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតណាមួយនៅរាជធានី ខេត្ត ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៅរាជធានី ខេត្តផ្សេង។
- សាមីអ្នកប្ដឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិក កបឃ.ស ក្នុងតំណែង មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធ ដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូង មានភាពមិនច្បាស់លាស់ ឬមិនដូចគ្នានឹងទិន្នន័យក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ឬ ឯ.អ របស់គាត់ ។

**ពាក្យបណ្ដឹងជំទាស់** អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង៖

- ក្នុងករណីដែលជននោះគ្មានសិទ្ធិបោះឆ្នោត ដោយសារមិនមែនជាតំណាងរាស្ត្រក្នុងតំណែង ឬមិនមែនជាសមាជិក កបឃ.ស ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ ។
- ក្នុងករណីដែលជននោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.ខប

#### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គឃ.ខប

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ។ ក្នុងករណីដែលអ្នកប្ដឹងមកប្ដឹងតវ៉ា ឬប្ដឹងជំទាស់ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងក្រៅពី ទ.១២០២ គឃ.ខប ត្រូវណែនាំអ្នកប្ដឹងឱ្យបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្ដឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្ដឹងជំទាស់**) ។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង សមាជិកដែលបានទទួលសិទ្ធិត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង

២- កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

គ. បន្ទាប់មកសមាជិកដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ សមាជិកដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងសួរកត់ត្រាក្នុងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ កម្មវត្ថុនៃបណ្ដឹងមិនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះ ពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ គធ.ឃប ទេ។ ដូចនេះ គធ.ឃប មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ឃ.២ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា "**ពាក្យបណ្ដឹងនេះ បានដាក់ក្រោយអំឡុងពេលកំណត់ ដូចមានចែងក្នុងប្រការ ៥.១៥.៧ នៃ ប.ន.ព.ស ដែលជាហេតុផ្ដល់សិទ្ធិ[២] ក្នុងការប្ដឹងមក គធ.ឃប ។ ដូចនេះ គធ.ឃប**

២ ការបាត់បង់សិទ្ធិ ដោយហេតុមិនបានបំពេញលក្ខខណ្ឌដែលច្បាប់តម្រូវឱ្យបំពេញក្នុងរយៈពេលមានកំណត់

**មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**”។ បន្ទាប់មកចុះហត្ថលេខា សរសេរ ឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.៣ ពាក្យបណ្ដឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិកដែលបានទទួលសិទ្ធិ ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ឃប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា “**ពាក្យបណ្ដឹងមិនមានបញ្ជាក់អត្តសញ្ញាណអ្នកប្ដឹង ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...**” ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ.៤ កម្មវត្ថុនៃបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង គោរពអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ចំពោះសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) សមាជិកដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ឃប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ (**ករណីប្ដឹងជំទាស់**) រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

### ១.២ ការដោះស្រាយពាក្យបណ្តឹងនៅ គឃ.ខប

**ក.** គឃ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

**ខ.** ក្នុងករណីដែល គឃ.ខប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គឃ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ (**ករណីប្តឹងជំទាស់**) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** គឃ.ខប ត្រូវបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដោយធ្វើកំណត់ហេតុសវនាការ។ យោងកំណត់ហេតុសវនាការ គឃ.ខប ត្រូវចាត់លេខាធិការសវនាការឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៣ (បី) ច្បាប់ (**ករណីប្តឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្តឹងជំទាស់**)។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គឃ.ខប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ (**ករណីបណ្តឹងជំទាស់**) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**ឃ.** បន្ទាប់ពី គឃ.ខប បើកសវនាការសម្រេចលើ**ពាក្យបណ្តឹងតវ៉ា** ក្នុងករណីដែល៖

- **បដិសេធលើបណ្តឹង៖** ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គឃ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្តឹង៖** ធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយ ទ.១២០៣ ដើម្បីបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ។

ង. បន្ទាប់ពី គធ.ខប បើកសវនាការសម្រេចលើ**ពាក្យបណ្តឹងជំទាស់** ក្នុងករណីដែល៖

- **បដិសេធលើបណ្តឹង៖** ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្តឹង៖** ជូនដំណឹងទៅអ្នកដែលត្រូវគេប្តឹងជំទាស់ថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយ ទ.១២០៣ ។

ច. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី២ ផ្នែកទី ១ ចំណុច ១.១ នៃសៀវភៅណែនាំនេះ (ទំព័រ៤៧)។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

ក. ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

ខ. អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (**ករណីប្តឹងតវ៉ា**) ឬចំនួន ៤ (បួន) ច្បាប់ (**ករណីប្តឹងជំទាស់**)។

គ. នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ដូចក្នុង **ចំណុច ១ (ទំព័រ ១)** និងការគោរពអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

ឃ. បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុសាកសួរនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។

ង. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

ង.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ឃប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ង.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងនោះ ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ច. ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ឃប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្ដឹងជំទាស់) រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

**២.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

**ក.** គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

**ខ.** ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ (**ករណីប្តឹងជំទាស់**) ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.** គ.ជ.ប ត្រូវបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដោយធ្វើកំណត់ហេតុសវនាការ។ យោងកំណត់ហេតុសវនាការ គ.ជ.ប ត្រូវចាត់គណៈលេខាធិការសវនាការឱ្យស្រង់សេចក្តីសម្រេចចូលក្នុង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ (**ករណីប្តឹងតវ៉ា**) ឬចំនួន ៥ (ប្រាំ) ច្បាប់ (**ករណីប្តឹងជំទាស់**)។ ទ.១២០៣ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ (**ករណីបណ្តឹងជំទាស់**) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**ឃ.** បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើ**ពាក្យបណ្តឹងតវ៉ា** ក្នុងករណីដែល៖

- **បដិសេធលើបណ្តឹង៖** ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្តឹង៖** ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ៤.១៥.២ នៃ ប.ន.ព.ស ។

ង. បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើ**ពាក្យបណ្ដឹងជំទាស់** ក្នុងករណីដែល៖

- **បដិសេធលើបណ្ដឹង៖** ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។
- **យល់ព្រមលើបណ្ដឹង៖** ជម្រាបអ្នកត្រូវគេប្ដឹងជំទាស់ថា គាត់អាចប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

ច. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី២ ផ្នែកទី១ ចំណុច ១.២ នៃសៀវភៅណែនាំនេះ (ទំព័រ៤៨)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គ.ជ.ប ។

ខ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

### ៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

ខ. នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

ឃ. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

គំនូសបំព្រួញទី២

ក. ករណីពាក្យបណ្តឹងតវ៉ា



## គំនូសបំព្រួញទី៣

### ខ. ករណីពាក្យបណ្តឹងជំទាស់



# ផ្នែកទី ៤
# នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ព.ស ដែលអាចនាំឱ្យមានការផាកពិន័យ

ផ្នែកទី ៤ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី ១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ព.ស ប.ន.ព.ស និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ឬ/និងអង្គការមិនមែនរដ្ឋាភិបាល ឬ/និងសមាគម ឬ/និងជនដែលជាមន្ត្រីបោះឆ្នោត ដែលអាចនាំឱ្យមានការផាកពិន័យ ដែលកើតមានឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រួមទាំងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

## I. ពាក្យបណ្ដឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម

ជនណាក៏ដោយមានសិទ្ធិដាក់ពាក្យបណ្ដឹង ចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ អ្នកប្ដឹងឬតំណាងអាចប្ដឹងបន្តទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ឬបន្តប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីកាលបរិច្ឆេទទទួលបាន ទ.១២០៣ របស់ គ.ជ.ប ។ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ដូចមានចែងក្នុង**ចំណុច ១ (ទំព័រ ១)** ។

## ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

### ១.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គធ.ខប

ក. អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។ អ្នកប្ដឹងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជូនខ្លួនបាន។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង សមាជិកដែលបានទទួលសិទ្ធិ ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

គ. បន្ទាប់មកសមាជិកដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរ យកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបាន ច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃ លើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ សមាជិកដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពី ការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃបន្ទាប់ពី ថ្ងៃកើតហេតុ ប្រធាន គជ.ខប ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ថា "**ពាក្យបណ្ដឹងនេះបានដាក់ក្រោយអំឡុងពេលកំណត់ដូចមាន ចែងក្នុងប្រការ ៩.១០ នៃ ប.ន.ព.ស ដែលជាហេតុផ្ដល់សិទ្ធិ ក្នុងការប្ដឹងមក គជ.ខប ។ ដូចនេះ គជ.ខប មិនអាចទទួល ពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**" ។ បន្ទាប់ មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គជ.ខប និងចុះ កាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើ ជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច ១ (ទំព័រ ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិ ឬ លិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ សមាជិកដែលបានទទួល សិទ្ធិ ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុច ខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបាន

បំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក ដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

**ឃ.៣** ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ **(ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** សមាជិកដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ខប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

## ១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

**ក.** បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើបណ្ដឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា ៖

១. ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.ព.ស ឬ ប.ន.ព.ស គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

២. កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើ ច.ប.ព.ស គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ថា " **ពាក្យបណ្ដឹងនេះ គធ.ខប មិនអាចទទួលមកដោះស្រាយ**

បានទេ ដោយហេតុថា ករណីនេះ ឬទាំងនេះគឺជាបទល្មើសព្រហ្មទណ្ឌ ដែលពុំមែនជាសមត្ថកិច្ចរបស់ គធ.ខប ” ។ បន្ទាប់មកចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៣. ពាក្យបណ្តឹងដែលប្តឹងពីអញ្ញាតជន គធ.ខប ត្រូវទទួលយកមកពិនិត្យ និងស្រាវជ្រាវរកអត្តសញ្ញាណរបស់អញ្ញាតជននោះ។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណជនប្រព្រឹត្តល្មើសមិនឃើញ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងទៅដើមបណ្តឹងវិញអំពីករណីនេះ។

៤. ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម៖
- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) នាក់ ជាសមាជិក
- មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម ១ (មួយ) នាក់ ជាលេខាធិការ។

ខ. ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភ័ស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះអាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹងអមដំណើរជាមួយបើមានការយល់ព្រមពីអ្នកប្តឹង។

គ. បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើ ច.ប.ព.ស និង ប.ន.ព.ស គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ឃ. ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់បានបំពានលើ ច.ប.ព.ស និង ប.ន.ព.ស **គជ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គជ.ខប ។**

ង. គជ.ខប ត្រូវធ្វើកំណត់ហេតុនៃការផ្សះផ្សា ដោយឱ្យគូភាគី ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ។

ច. ក្នុងការផ្សះផ្សា ប្រសិនបើភាគីទំនាស់ ៖

ច.១ **ព្រមព្រៀងគ្នា** គជ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប ។

ច.២ **មិនព្រមព្រៀងគ្នា** គជ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ គជ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្ដង។

ឆ. គជ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹងដោយមានកំណត់ហេតុសវនាការ សេចក្ដីសម្រេច និង ទ.១២០៣ ចំនួន ៤ (បួន) ច្បាប់ ដោយមានចុះហត្ថលេខារបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គជ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ជ. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា និងក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី២ ផ្នែកទី១ ចំណុច ១.១ នៃសៀវភៅណែនាំនេះ (ទំព័រ៤៧)។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

ក. ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្ដីសម្រេចរបស់ គធ.ខប អាចប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។ អ្នកប្ដឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់។

ខ. នៅពេលបានទទួលពាក្យបណ្ដឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទិ៍៖

១- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង

២- កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ ។

គ. បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុសាកសួរនោះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។

ឃ. បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា៖

ឃ.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

ឃ.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុង **ចំណុច១ (ទំព័រ១)** ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងនោះ ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

ង. ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប មានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (**ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់**) មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

ក.១ ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.ព.ស ឬ ប.ន.ព.ស គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូន

អ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.២** កម្មវត្ថុ និងមូលហេតុនៃបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពាន ច.ប.ព.ស គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៣** ពាក្យបណ្ដឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅគធ.ឧប គ.ជ.ប ត្រូវពិនិត្យសម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ក.៤** ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូច**ចំណុច ១ (ទំព័រ ១)** គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

**ខ.** គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

**គ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកបណ្ដឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្ដឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹង ដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការ

ស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្ដឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្ដឹង ដើម្បីជូនជ្រាបថាពាក្យបណ្ដឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ឃ.** បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹង គ.ជ.ប ត្រូវ**បើកសវនាការដោះស្រាយបណ្ដឹងតាមពេលវេលាសមស្របជាបន្ទាន់**។

**ង.** គ.ជ.ប ត្រូវបើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើបណ្ដឹងដោយមានកំណត់ហេតុសវនាការ សេចក្ដីសម្រេច និង ទ.១២០៣ ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្ដីសម្រេចនេះត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ច.** សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងជំពូកទី២ ផ្នែកទី១ ចំណុច ១.២ នៃសៀវភៅណែនាំនេះ (**ទំព័រ៤៨**)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ក.** ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីកាលបរិច្ឆេទទទួលបាន ទ.១២០៣ របស់ គ.ជ.ប ។

ខ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**៣.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹង ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្ដឹង។

ខ. នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងជន ដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម

គំនូសបំព្រួញទី៤

I. ការប្តឹងពីជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម



## II. ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស ប.ន.ព.ស និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង គ.ក.ប/គ.ក.រ ឬ គធ.ឧប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក.** ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្តឹងទៅ គធ.ឧប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ (**ទំព័រ ១៩ ដល់ ២៨**)។

**ខ.** ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គធ.ឧប ឬមន្ត្រី លគធ.ឧប ឬ មន្ត្រី គ.ជ.ប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានណែនាំក្នុងសៀវភៅណែនាំនេះ (**ទំព័រ ២៤ ដល់ ២៨**)។

**គ.** ពាក្យបណ្តឹងពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្តឹងទៅរដ្ឋសភាដោយអនុលោមតាម ច.គ.ជ.ប ។

ពាក្យបណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹងដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយពាក្យបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

**ក្នុងករណីដែលរកឃើញថា៖**

- សមាជិក ឬមន្ត្រីនោះពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស និង ប.ន.ព.ស ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្រប តាម ច.ប.ព.ស ។
- សមាជិក ឬមន្ត្រីនោះបានគោរពតាម ច.ប.ព.ស និង ប.ន.ព.ស ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

# គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង ពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

គំនូសបំព្រួញទី៥

II. ការប្ដឹងពីជនដែលជាមន្ត្រីបោះឆ្នោត



## ផ្នែកទី ៥
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត

ផ្នែកទី ៥ នេះ ណែនាំអំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតដែលកើតមានឡើងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត និងពាក្យបណ្តឹងពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលកើតមានឡើងក្នុងតំបន់ណាមួយ នៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។

### ១. ការតវ៉ា ឬការជំទាស់ និងការដោះស្រាយនៅ គ.ក.ប/គ.ក.រ

#### ១.១ ការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

ក. ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិតវ៉ា ឬជំទាស់ផ្ទាល់ភ្លាមៗទៅប្រធាន គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនានាក្នុងពេលកំពុងបោះឆ្នោត ឬរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខ្លួនបំពេញការងារសង្កេតការណ៍។

ខ. អ្នកតវ៉ា ឬជំទាស់ ត្រូវបង្ហាញអំពីមូលហេតុ ឬ/និងភ័ស្តុតាងដែលនាំឱ្យប្រធាន គ.ក.ប/គ.ក.រ ជឿថាមានភាពមិនប្រក្រតី ឬមានការបំពានលើ ច.ប.ព.ស ឬ ប.ន.ព.ស ។

#### ១.២ ការដោះស្រាយអំពីការតវ៉ា ឬការជំទាស់នៅ គ.ក.ប/គ.ក.រ

ក. ប្រធាន គ.ក.ប/គ.ក.រ ត្រូវដោះស្រាយភ្លាមនូវការតវ៉ា ឬការជំទាស់។

ខ. ប្រសិនបើយល់ឃើញថាការតវ៉ា ឬការជំទាស់សមហេតុផល ប្រធាន គ.ក.ប/គ.ក.រ ត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ឬរាប់សន្លឹកឆ្នោត ដើម្បីស្តាប់ការតវ៉ា ឬការជំទាស់របស់ភ្នាក់ងារគណបក្សនយោបាយនោះ បន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប/គ.ក.រ ដទៃទៀត ដើម្បីដោះស្រាយភាពមិនប្រក្រតីទាំងនោះជាបន្ទាន់។

គ. ប្រសិនបើយល់ឃើញថាការតវ៉ា ឬការជំទាស់មិនសមហេតុផល ប្រធាន គ.ក.ប/គ.ក.រ មានសិទ្ធិបដិសេធការតវ៉ា ឬការជំទាស់នោះ ដោយត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះ។

ឃ. ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែតវ៉ា ឬជំទាស់ គ.ក.ប/គ.ក.រ ត្រូវកត់ត្រាខ្លឹមសារនៃការតវ៉ា ឬជំទាស់នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ឬកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយឱ្យអ្នកតវ៉ា ឬជំទាស់ចុះហត្ថលេខាលើកំណត់ហេតុនេះ។

ង. ក្នុងករណី ភ្នាក់ងារគណបក្សនយោបាយមិនយល់ព្រមចុះហត្ថលេខា ខ្លឹមសារនៃការតវ៉ា ឬជំទាស់នោះ មិនត្រូវបានកត់ត្រាក្នុង ទ.១១០១ ឬ ទ.១១០២ ឡើយ។

ច. ការសម្រេចរបស់ប្រធាន គ.ក.ប/គ.ក.រ ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន បន្ទាប់មកប្រធាន គ.ក.ប/គ.ក.រ ត្រូវប្រកាសបន្តដំណើរការបោះឆ្នោត ឬរាប់សន្លឹកឆ្នោតតទៅទៀត។

ឆ. ប្រសិនបើមានការស្នើសុំ ប្រធាន គ.ក.ប/គ.ក.រ ត្រូវផ្តល់ ទ.១២០២ ដល់អ្នកតវ៉ា ឬជំទាស់ ដើម្បីប្តឹងបន្តទៅ គធ.ខប និងជម្រាបគាត់ថា រយៈពេលនៃការប្តឹងត្រូវធ្វើជាបន្ទាន់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅ គធ.ខប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ២.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប

ក. ភ្នាក់ងារគណបក្សនយោបាយ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការតវ៉ា ឬការជំទាស់ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ អាចដាក់ពាក្យបណ្តឹងទៅ គធ.ខប ដោយត្រូវធ្វើឡើងជាបន្ទាន់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅ គធ.ខប នៅល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

ខ. ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្តឹង ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្តិតមេដៃលើ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចមានចែងក្នុង**ចំណុចទី១ (ទំព័រ ១)** នៃសៀវភៅណែនាំនេះ។

គ. ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ ដូចចែងក្នុង**ចំណុច ក (ទំព័រ ៣៣)** ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹងថាពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ។

ឃ. ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ គធ.ខប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ង. ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ ដូចចែងក្នុងចំណុច ក (ទំព័រ ៣៣) និងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ លគធ.ខប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គធ.ខប ប្រើក្នុងពេលប្រជុំសម្រេច និងជម្រាបអ្នកប្តឹងថា

គធ.ខប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធក្នុងអំឡុងពេលនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងរាជធានីខេត្ត។

## ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

**ក.** ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់មានពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលអាចប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ខប ត្រូវ៖

**ក.១** ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្ដឹង។

**ក.២** បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៨.២៨ នៃ ប.ន.ព.ស ។

**ក.៣** អនុញ្ញាតឱ្យដើមបណ្ដឹង ឬតំណាង ភ្នាក់ងារគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលការអនុវត្តនីតិវិធីដូចចែងក្នុងចំណុច **ក.១** និង **ក.២** ខាងលើ។

**ខ.** ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច **ក.១** និង **ក.២** ខាងលើ គធ.ខប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីណាមួយក្នុងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងនោះ ដោយធ្វើកំណត់ហេតុផង។ ក្នុងករណី គធ.ខប បដិសេធលើពាក្យបណ្ដឹង ប្រធាន គធ.ខប ត្រូវ៖

**ខ.១** ចារយល់ព្រមលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និង

សន្លឹកឆ្នោត របស់ក្រុមត្រួតពិនិត្យលទ្ធផល រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ឃប ព្រមទាំងដាក់បង្ហាញចំពោះ អ្នកប្ដឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន។

ខ.២ ចាត់មន្ត្រី លគធ.ឃប ឱ្យបំពេញ ទ.១២០៣ យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ចំនួន ៣ (បី) ច្បាប់ ព្រមទាំងចុះហត្ថលេខាផង។

ខ.៣ ចុះហត្ថលេខា បោះត្រា គធ.ឃប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលមន្ត្រី លគធ.ឃប បានបំពេញ រួចចាត់ចែងប្រគល់ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ខ.៤ ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ឃប ទៅ គ.ជ.ប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។

ខ.៥ ប្រគល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ជូនអ្នកប្ដឹងតវ៉ាសម្រាប់ប្ដឹងបន្តទៅ គ.ជ.ប (ប្រសិនបើគាត់ស្នើសុំ)។

គ. ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច **ក.១** និង **ក.២** ខាងលើ គធ.ឃប បានរកឃើញភ័ស្តុតាងបញ្ជាក់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយក្នុងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គធ.ឃប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងនោះ ដោយធ្វើកំណត់ហេតុផង។ ក្នុងករណី គធ.ឃប យល់ព្រមតាមពាក្យបណ្ដឹង ប្រធាន គធ.ឃប ត្រូវ៖

គ.១ ចារព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត លើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់

ក្រុមត្រួតពិនិត្យលទ្ធផល រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ឧប ព្រមទាំងដាក់បង្ហាញចំពោះអ្នកប្ដឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

**គ.១** ចាត់មន្ត្រី លគធ.ឧប ឱ្យបំពេញ ទ.១២០៣ យល់ព្រមតាមពាក្យបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុ ចំនួន ៣ (បី) ច្បាប់ ព្រមទាំងចុះហត្ថលេខាផង។

**គ.២** ចុះហត្ថលេខា បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលមន្ត្រី លគធ.ឧប បានបំពេញ រួចចាត់ចែងប្រគល់ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្ដឹងថា គធ.ឧប នឹងលើកសំណើទៅ គ.ជ.ប សុំព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ ព្រមទាំងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដោយឡែកបញ្ជូនទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពី គធ.ឧប សម្រេចយល់ព្រមតាមពាក្យបណ្ដឹង ដើម្បី គ.ជ.ប ពិនិត្យសម្រេច។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ៣.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

**ក.** អ្នកប្ដឹងតវ៉ា ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គធ.ឧប មានសិទ្ធិប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គធ.ឧប ។

**ខ.** អ្នកប្ដឹងតវ៉ា ឬតំណាងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុង**ចំណុចទី១ (ទំព័រ ១)** នៃសៀវភៅណែនាំនេះ។

**គ.** ចំពោះពាក្យបណ្ដឹងដែលបានទទួលក្រោយរយៈពេលកំណត់ដូចចែងក្នុង**ចំណុច ក ខាងលើ** គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់

ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ឃ. ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ង. ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ ដូចចែងក្នុង **ចំណុច ក (ទំព័រ ៣៧)** មានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ និងមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវតាមច្បាប់ (**ករណីសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់**) មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គ.ជ.ប ប្រើក្នុងពេលសវនាការ និងជម្រាបអ្នកប្តឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ។

### ៣.២ ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ក. នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប អំពីករណីនៃពាក្យបណ្តឹង ដោយភ្ជាប់ ទ.១២០២ ដែលបានទទួល និង ទ.១២០៣ របស់ គធ.ខប

បដិសេធពាក្យបណ្តឹង ដូចមានចែងក្រោម**ចំណុច ខ (ទំព័រ ៣៥)** ដែលត្រូវដកចេញពីកញ្ចប់ "ឃ ពិសេស" ដើម្បីសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផល ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ នៅចំពោះមុខអ្នកប្តឹង ឬតំណាង ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍។

ខ. បន្ទាប់ពីក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គ.ជ.ប បញ្ចប់ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តមួយ ឬច្រើនចំណុះភូមិភាគហើយ ក្នុងករណី គ.ជ.ប សម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

- **ខ.១** ចារយល់ព្រមលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល និងតារាងត្រួតពិនិត្យលទ្ធផល ដែលស្នើសុំបដិសេធលទ្ធផលនៃការបោះឆ្នោត រួចចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។
- **ខ.២** ចាត់គណៈលេខាធិការសវនាការ ឱ្យបំពេញ ទ.១២០៣ បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ តាមចំនួនចាំបាច់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលនៃការបោះឆ្នោត។ ទ.១២០៣ នេះ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធាន គ.ជ.ប ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។
- **ខ.៣** ប្រកាសថា គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យ

បោះឆ្នោតទាំងអស់នៃរាជធានី ខេត្តនោះ ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធ។

**គ.** បន្ទាប់ពីក្រុមត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គ.ជ.ប បញ្ចប់ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តមួយ ឬច្រើនចំណុះភូមិភាគហើយ ក្នុងករណី គ.ជ.ប សម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

**គ.១** ចារយល់ព្រមលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល និងតារាងត្រួតពិនិត្យលទ្ធផល ដែលស្នើសុំទទួលយកលទ្ធផលនៃការបោះឆ្នោត រួចចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។

**គ.២** ចាត់គណៈលេខាធិការសវនាការ ឱ្យបំពេញ ទ.១២០៣ បដិសេធពាក្យបណ្តឹង និងទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ តាមចំនួនចាំបាច់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធពាក្យបណ្តឹង។ ទ.១២០៣ នេះ ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធាន គ.ជ.ប ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**គ.៣** ប្រគល់របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល តារាងត្រួតពិនិត្យលទ្ធផល និង ទ.១២០៣ របស់ គ.ជ.ប ដែលសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងឯកសារក្នុងស្រោមសំបុត្រធំ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៅ គ.ជ.ប ដើម្បីមុខការ។

**ឃ.** សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត

គំនូសបំព្រួញទី៦



## ផ្នែកទី ៦
## បណ្តឹងក្នុងដំណាក់កាលប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគ ឬតំណាង មានសិទ្ធិប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដោយត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតី កាលបរិច្ឆេទ ទីន្លែងប្រព្រឹត្តខុស ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ព្រមទាំងឯកសារ ឬភ័ស្តុតាងដទៃទៀត ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៣៨.៦ នៃ ប.ន.ព.ស ។

ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ មិនបានទទួលពាក្យបណ្តឹងតវ៉ាណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទេ។

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

#### ១.១ ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

ក. អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់។

ខ. ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

គ. ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។

ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

ឃ. ចំពោះពាក្យបណ្ដឹងដែលបានទទួលក្នុងរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត មានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ និងមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវតាមច្បាប់ **(ករណីសាមីខ្លួនមិនចូលខ្លួនប្ដឹងផ្ទាល់)** មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅទីស្ដីការ គ.ជ.ប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គ.ជ.ប ប្រើក្នុងពេលសវនាការ។

## ១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

ក. ចំពោះពាក្យបណ្ដឹងតវ៉ាមានឯកសារ ឬភ័ស្ដុតាងគ្រប់គ្រាន់ ដែលបានដាក់នៅ គ.ជ.ប ស្របពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត គ.ជ.ប ត្រូវបើកសវនាការដោះស្រាយពាក្យបណ្ដឹងតវ៉ានោះ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង។ នីតិវិធីសម្រាប់បើកសវនាការដោះស្រាយពាក្យបណ្ដឹងតវ៉ា ដែលបានដាក់នៅ គ.ជ.ប ត្រូវបានកំណត់ដោយយោងតាមសិទ្ធិអំណាចរបស់ គ.ជ.ប និងការកំណត់ក្នុង ប.ន.ព.ស ។

ខ. បន្ទាប់ពី គ.ជ.ប សម្រេចលើពាក្យបណ្ដឹងតវ៉ា ក្នុងករណីដែលៈ

- **សម្រេចយល់ព្រមតាមពាក្យបណ្ដឹងៈ** គ.ជ.ប ត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន និងត្រូវចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ។

- **សម្រេចបដិសេធពាក្យបណ្ដឹង៖** គ.ជ.ប ត្រូវចេញ ទ.១២០៣ ទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ និងជម្រាបអ្នកប្ដឹង ឬតំណាងថា គាត់អាចប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីពេលបានទទួល ទ.១២០៣ របស់ គ.ជ.ប ។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ២.១ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគ ឬតំណាង មានសិទ្ធិប្ដឹងតវ៉ាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ឬអ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ របស់ គ.ជ.ប ។

ខ. នីតិវិធីនៃការដាក់ និងការទទួលពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ២.២ ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ក. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

ខ. នីតិវិធីនៃការដោះស្រាយពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

គ. ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបដិសេធ ឬយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

ឃ. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត

គំនូសបំព្រួញទី៧



## ផ្នែកទី ៧
## នីតិវិធីអនុវត្តសេចក្តីសម្រេចស្ថាពរចំពោះការដាក់ទណ្ឌកម្មពិន័យជាប្រាក់

ការអនុវត្តសេចក្តីសម្រេចស្ថាពរដាក់ទណ្ឌកម្មពិន័យជាប្រាក់ទៅលើជនល្មើស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

**ក.** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ជាអ្នកទទួលខុសត្រូវរៀបចំសំណុំឯកសារអនុវត្តសេចក្តីសម្រេចស្ថាពរ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ខ.** តាមរយៈការសម្រេចឱ្យអនុវត្តសេចក្តីសម្រេចស្ថាពរ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចាត់វិធានការជូនដំណឹងទៅជនដែលត្រូវពិន័យឱ្យចូលខ្លួនមកអនុវត្តសេចក្តីសម្រេចដាក់ទណ្ឌកម្មពិន័យជាប្រាក់នោះដោយស្ម័គ្រចិត្ត ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីបង្គាប់។

**គ.** បើដល់ពេលកំណត់ ជនដែលត្រូវពិន័យមិនព្រមបង់ប្រាក់ពិន័យតាមសេចក្តីជូនដំណឹងទេនោះ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវរៀបចំរបាយការណ៍ និងលើកសំណើតាមរយៈអគ្គលេខាធិការដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ និងសម្រេច។

**ឃ.** ក្នុងករណីដែល គ.ជ.ប យល់ឃើញថាគ្មានស្ថានភាពណាមួយដែល គ.ជ.ប ត្រូវពន្យារពេល ឬបន្ធូរបន្ថយ ឬលើកលែងទណ្ឌកម្មពិន័យជាប្រាក់ ឬរំលត់ការដាក់ទណ្ឌកម្មទេនោះ គ.ជ.ប អាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.ប ទារប្រាក់ពីជនដែលត្រូវពិន័យជូន គ.ជ.ប។

**ង.** ប្រាក់ពិន័យដែលទទួលបាន ត្រូវដាក់ចូលជាថវិកាជាតិ។

# ជំពូកទី ២
# សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការ ដោះស្រាយពាក្យបណ្តឹង

## ផ្នែកទី ១
## សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

គជ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ គជ.ខប បើកការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចបានចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ១. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គជ.ខប ឬ គ.ជ.ប ។

#### ១.១ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គជ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ និងការសម្រេចរបស់ខ្លួន តាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សាហៅថា **ក្រុមប្រឹក្សាប្រជុំផ្សះផ្សា** ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេចហៅថា**ក្រុមប្រឹក្សាប្រជុំសម្រេច** ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការហៅថា**ក្រុមប្រឹក្សាជំនុំជម្រះ**។ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី លគធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ

កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត និងមិនត្រូវមានសំឡេងអនុបវាទឡើយ។

### ១.២ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្តឹង ហៅថា **ក្រុមប្រឹក្សាជំនុំជម្រះ**។

សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ជាគណៈលេខាធិការសវនាការ។

លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ៥០ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវមានសំឡេងអនុបវាទឡើយ។

## ២. សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

### ២.១ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ឌប

ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ឌប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។ ដោយឡែកការប្រជុំសម្រេច ឬ/និងសវនាការអាចកោះហៅសាក្សីបាន។

ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬអង្គសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី ៣ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង។

### ២.២ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះអាចបញ្ចូលរឿងក្តីក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរហើយ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅបន្តប្រព្រឹត្តល្មើសទៀត ហើយបើមានបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

គ.ជ.ប មានសិទ្ធិធ្វើការស៊ើបអង្កេតលើករណីមាន ឬគ្មានបណ្តឹងក្នុងគោលបំណងឱ្យមានការគោរព ច.ប.ព.ស និង ប.ន.ព.ស និងដើម្បីឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

ក្នុងពេលសវនាការ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គសវនាការ ហើយមានសិទ្ធិបណ្ដេញឱ្យចេញពីបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកសវនាការដោះស្រាយពាក្យបណ្ដឹង ដូចមានចែងក្នុងឧបសម្ព័ន្ធទី ៣ ស្ដីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្ដឹង។

# ផ្នែកទី ២
# សិទ្ធិ និងភារកិច្ចរបស់គូភាគី ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង និងសាក្សី

## ១. សិទ្ធិ និងភារកិច្ចរបស់គូភាគី

ក្នុងករណីគូភាគីមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬអ្នកការពារក្តី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងបណ្តឹងឱ្យចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជនុំជម្រះមុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិតែមិនតម្រូវឱ្យមានសាក្សីទេ។

គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាង ដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ (តំណាងត្រូវតែជានីតិជន[៣])។

លិខិតប្រគល់សិទ្ធិនេះត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការយ៉ាងតិច ២ (ពីរ) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ។

ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

គូភាគីមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ព.ស និង ប.ន.ព.ស ។

---

[៣] ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ

## ២. សិទ្ធិ និងភារកិច្ចរបស់ដើមបណ្ដឹង

ដើមបណ្ដឹងអាចដកពាក្យបណ្ដឹងទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

ការដកពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្ដឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្ដឹងចោលដោយចេញ ទ.១២០៣។

ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្ដឹងដកពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

ដើមបណ្ដឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិផងដែរ។ ចុងចម្លើយអាចបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្ដីរបស់ខ្លួន។

ដើមបណ្ដឹង ឬ/និងជនរងគ្រោះមានវិសមិតភាព[៤] រវាងឋានៈជាដើមបណ្ដឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី។ ដើមបណ្ដឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្ដល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

## ៣. សិទ្ធិ និងភារកិច្ចរបស់ចុងចម្លើយ

ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងបណ្ដឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលទទួលសិទ្ធិផងដែរ។ ចុងចម្លើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្ដីរបស់ខ្លួន។

---

[៤] ភាពដែលមិនអាចមាន ឬប្រកបកិច្ចការចូលគ្នាបាន

ចុងចម្លើយអាចបង្ហាញភស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយពីភស្តុតាងដែលមានដែរ។ ចុងចម្លើយអាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងអំពីភស្តុតាងដែលគេមាន។

## ៤. សិទ្ធិ និងភារកិច្ចរបស់មេធាវី ឬតំណាង

មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ភាគីអាចស្នើឱ្យ គជ.ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើដោយមន្ត្រី លគជ.ខប ឬមន្ត្រីរាជការ គ.ជ.ប ដែលបានចាត់តាំង។

## ៥. សិទ្ធិ និងភារកិច្ចរបស់សាក្សី

សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវចំពោះមុខច្បាប់អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (**ខ្លឹមសារសម្បថមានក្នុងឧបសម្ព័ន្ធទី ៤ ស្តីពីនីតិវិធី និងខ្លឹមសារនៃសម្បថ**)។

សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នារង់ចាំការអញ្ជើញឱ្យចូលមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។ ហើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ។

សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

## ផ្នែកទី ៣
## នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង (មានចែងក្នុងឧបសម្ព័ន្ធទី៣ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង)។

### ១. ប្រភេទសវនាការ

ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

**សវនាការសង្ខេប** ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

**សវនាការតទល់** ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ។

**សវនាការសួរដេញដោល** ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តីជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ២. ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គឺភាសាខ្មែរ។

ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ៣. ពេលវេលាដោះស្រាយពាក្យបណ្តឹង

អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀល ចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី។ ក្នុងករណីចាំបាច់ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។

ក្នុងករណីដែលថ្ងៃកំណត់ដោះស្រាយបណ្តឹង និងសម្រេចលើបណ្តឹងចំថ្ងៃបុណ្យជាផ្លូវការ អង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការត្រូវលើកទៅថ្ងៃបន្ទាប់។

ក្នុងកម្មវិធីមួយពេលនៃការបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬជំនុំជម្រះច្រើនករណីនៃបណ្តឹងបាន។

## ៤. ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬបើកសវនាការ

### ៤.១ ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬអង្គជំនុំជម្រះនៅ គធ.ខប

គធ.ខប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេច ឬ/និងជំនុំជម្រះនៅថ្នាក់របស់ខ្លួន ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ព.ស និង ប.ន.ព.ស ។

គធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុន ពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

### ៤.២ ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ព.ស និង ប.ន.ព.ស ។

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវជានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលា យ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ។

## ៥. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការមានភារកិច្ចដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅធ្វើសម្បថ (**ករណីប្រជុំសម្រេច ឬសវនាការ**)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរ នៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការដែលត្រូវស្រង់វត្តមានសាក្សី។
- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោយដៃ ឬដោយកុំព្យូទ័រ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ មិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខាលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច និងភាគីពាក់ព័ន្ធ ។
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធ តាមការបង្គាប់ពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា រួចដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ។
- អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

## ៦. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

នៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវៈ

ទី១. ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ទី២. ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ

ទី៣. បង្គាប់លេខាធិការអង្គប្រជុំសម្រេច ឬប្រធានគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្តឹង ចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ)។

មុននឹងចាប់ផ្តើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្តឹងថា **តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្តឹង ឬមានការកែប្រែឬទេ?** ប្រសិនបើៈ

- ដើមបណ្តឹងឆ្លើយថាខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបង្គាប់ឱ្យលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្តឹងផ្តិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សារឿងក្តីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬជំនុំជម្រះរឿងក្តីផ្សេងទៀត (ប្រសិនបើមាន)។
- ដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្តើមដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្តឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្តី សួរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយមុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬការសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹងពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះមិនត្រូវបានអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។

ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

### ៧. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេនោះ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច។

ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតជូនដំណឹងហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកបណ្តឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវលុបបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប។

ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង

ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយក ទ.១២០៣ នោះលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "**អ្នកប្តឹង ឬតំណាង ឬអ្នកត្រូវគេប្តឹង ឬតំណាងមិនព្រមទទួល ទ.១២០៣**" ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយក ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹង ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួល ទ.១២០៣ រួចហើយ។

## ៨. មធ្យោបាយបង្ហាញភ័ស្តុតាង

មធ្យោបាយបង្ហាញភ័ស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការនេះ។

ភ័ស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរព ច.ប.ព.ស និង ប.ន.ព.ស ។

ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន។

## ៩. ការប្រើប្រាស់ និងបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣)

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកលើកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ការបំពេញ

ទ.១២០៣ នៅ គធ.ខប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនសាមីអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ទ.១២០៣ របស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្តឹងជំទាស់ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច ។ ទ.១២០៣ ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួល ទ.១២០៣ នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ក្នុងករណី៖

- ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់។

- ភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូន ទ.១២០៣ ដោយមានដីកាអម ទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួល ទ.១២០៣ ។

## ១០. ទម្រង់ផ្សេងៗសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ

គជ.ខប និង គ.ជ.ប មានទម្រង់ផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការមានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃ គជ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ។

លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងទុកជាឯកសារ ១ (មួយ) ច្បាប់។

កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គជ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេច របស់ក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះអាចថតចម្លងផ្តល់ជូនគូភាគីបាន ប្រសិនបើមានការស្នើសុំ។

# ឧបសម្ព័ន្ធទី ១
# ទម្រង់បែបបទពាក្យបណ្តឹង (ឧ.១២០២)

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ពាក្យបណ្តឹង (ឧ.១២០២)

I. **សម្រាប់អ្នកប្តឹង**

១. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង ៖ ............ ភេទ ...... ថ្ងៃខែឆ្នាំកំណើត ............
- ទីលំនៅបច្ចុប្បន្ន ៖ ផ្ទះលេខ______ ផ្លូវ______ ភូមិ______ ឃុំ សង្កាត់______
  ក្រុង ស្រុក ខណ្ឌ______ រាជធានី ខេត្ត______
- តួនាទី/មុខងារ ៖ ☐ប្រជាពលរដ្ឋ ☐ភ្នាក់ងារគណបក្សនយោបាយ ______
  ☐ផ្សេងៗ______ ទូរស័ព្ទទាក់ទង______

២. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| រាជធានី ខេត្ត | | | ក្រុង ស្រុក ខណ្ឌ | ឃុំ សង្កាត់ | | | | លេខកូដការិយាល័យ | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខកូដ | | | | លេខកូដ | | | | | | | |

៣. កម្មវត្ថុនៃបណ្តឹង ៖ ............

............

............

............

៤. មូលហេតុនៃការប្តឹង ៖ ............

............

............

............

............

............

............

............

............(ករណីក្រដាសបន្ថែមសូមសរសេរនៅខាងខ្នង)

៥. កាលបរិច្ឆេទ ៖ ......../......../........

៦. ហត្ថលេខា ឬស្នាមមេដៃអ្នកប្តឹង (ប្រសិនបើអ្នកជាតំណាង ត្រូវមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរភ្ជាប់មកជាមួយ)

II. **សម្រាប់មន្ត្រីទទួលបន្ទុកការងារបោះឆ្នោត**

______ ថ្ងៃទី______ ខែ______ ឆ្នាំ______

| លេខពាក្យបណ្តឹង | កាលបរិច្ឆេទទទួលពាក្យបណ្តឹង | កាលបរិច្ឆេទប្រជុំសម្រេច ឬបើកសវនាការ |
|---|---|---|
| | ____/____/____ | |
| | ម៉ោង______ ព្រឹក☐, រសៀល☐ | ____/____/____ |

**ហត្ថលេខា និងឈ្មោះ**

ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញដោយអ្នកប្តឹងតវ៉ា ឬប្តឹងជំទាស់

# ឧបសម្ព័ន្ធទី ២
# ទម្រង់បែបបទសម្រង់សេចក្តីសម្រេច (ទ.១២០៣)

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

## សម្រង់សេចក្តីសម្រេច (ទ.១២០៣)

១. លេខបណ្តឹង/សំណុំរឿង និងសេចក្តីសម្រេច

- បណ្តឹង/សំណុំរឿងលេខ__________ ចុះថ្ងៃទី______ ខែ________ ឆ្នាំ________ វេលាម៉ោង________
- សេចក្តីសម្រេចលេខ__________________ ចុះថ្ងៃទី__________ ខែ__________ ឆ្នាំ__________

២. អត្តសញ្ញាណអ្នកប្តឹង

- ឈ្មោះអ្នកប្តឹង__________________ ភេទ__________ ថ្ងៃខែឆ្នាំកំណើត__________
- ទីលំនៅបច្ចុប្បន្នផ្ទះលេខ__________ ផ្លូវ__________ ភូមិ__________ ឃុំ សង្កាត់__________
  ក្រុង ស្រុក ខណ្ឌ__________________ រាជធានី ខេត្ត__________
- តួនាទី/មុខងារ__________________________________

៣. កម្មវត្ថុនៃបណ្តឹង__________________________________

__________________________________________

__________________________________________

៤. លក្ខណៈសម្គាល់នៃទីកន្លែងពាក់ព័ន្ធនឹងបណ្តឹង

| | | |
|---|---|---|
| រាជធានី ខេត្ត | | |
| លេខកូដ | | |

| |
|---|
| ក្រុង ស្រុក ខណ្ឌ |
| |

| | | | |
|---|---|---|---|
| ឃុំ សង្កាត់ | | | |
| លេខកូដ | | | |

| | | | |
|---|---|---|---|
| លេខកូដការិយាល័យ | | | |
| | | | |

### សម្រេច

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

**បានស្រង់ត្រឹមត្រូវតាមច្បាប់ដើម**

**បានឃើញ**

ថ្ងៃទី__________ ខែ__________ ឆ្នាំ__________

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច**
**ហត្ថលេខា និងត្រា**

**លេខាធិការសវនាការ ឬអង្គប្រជុំសម្រេច**
**ហត្ថលេខា**

ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញដោយក្រុមប្រឹក្សាជំនុំជម្រះ ឬអង្គប្រជុំសម្រេច

## ឧបសម្ព័ន្ធទី ៣
## បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា
## ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការដូចជា៖
- ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣. ហាមយកក្មេងអាយុក្រោម១៨ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦. ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

៧. ក្នុងករណីជនណាបង្កបញ្ហាអ្វីមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះ ចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវទទួលទោសតាមច្បាប់ជាធរមាន។

# ឧបសម្ព័ន្ធទី ៤
# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូបបូជានៅចំពោះមុខវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវវត្តបាពយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិតតាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយបងប្អូន កូនចៅ ឱ្យក្រហេមហោម ខ្សត់ទ្រព្យ រងទុក្ខវេទនាអស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិតព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរមានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៌ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អានលុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿងសមដូចប្រាថ្នាកុំបីអាក់ខានឡើយ។

### ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ បើខ្ញុំឆ្លើយមិនពិតដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៌ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្តជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

បោះពុម្ព និងផ្សព្វផ្សាយដោយ

គ.ជ.ប

ឆ្នាំ ២០១៧

អាសយដ្ឋាន : ទីស្តីការ គ.ជ.ប អគារ H ក្នុងបរិវេណក្រសួងមហាផ្ទៃ
ស្ថិតនៅមហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារៈ ០២៣ ២១៤ ៣៧៤, ២១៤ ២៣១, ០១២ ៨៥៥ ០១៨

Address : NEC Headquarters, Building H, Ministry of Interior Compound, Preah Norodom Blvd,
Sangkat Tonle Basac, Khan Chamkar Mon, Phnom penh, Cambodia
Phone / Fax: 023 214 374, 214 231, 012 855 018
E-mail: necinfo@forum.org.kh, www.necelect.org.kh, www.voterlist.org.kh